វេទិកាថ្នាក់ជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ
រាជធានីភ្នំពេញ 5-7 ខែវិច្ឆិកា ឆ្នាំ 2013

# សុន្ទរកថាស្វាគមន៍

## ដោយ ឯកឧត្តមរស់ សីលាវ៉ា, អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៣ សណ្ឋាគារសូហ្វីតែល ភូគីត្រា រាជធានីភ្នំពេញ

*ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយស ជាទីគោរព*

ខ្ញុំមានសេចក្តីសោមនស្សរីករាយជាខ្លាំង ដែលបានចូលរួមក្នុងពីធីបើកវគ្គនៃថ្ងៃចុងក្រោយរបស់វេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុនេះ។

ដំណើរការវេទិការរយៈពេលពីរថ្ងៃកន្លងមក បានផ្តល់ឱកាសឱ្យយើងធ្វើការពិភាក្សាលម្អិតពីការងារដែលក្រសួងពាក់ព័ន្ធ ក្រសួងបរិស្ថាន និងដៃគូរបស់ខ្លួន បានអនុវត្តក្នុងអំឡុងពេលពីរឆ្នាំកន្លងមក ដើម្បីរៀបចំនូវផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដ៏សមស្របមួយសម្រាប់កម្ពុជា។ គម្រោងជាច្រើនទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដែលត្រូវបានអនុវត្តរហូតមកដល់បច្ចុប្បន្ន បានជួយឱ្យយើងមានការយល់ដឹងកាន់តែប្រសើរឡើងពីវិធីសាស្ត្រដែលមានប្រសិទ្ធភាពសម្រាប់ ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងបរិបទនៃប្រទេសកម្ពុជា។ ឥឡូវនេះ ជាមួយនឹងការប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ កម្ពុជា យើងមានមូលដ្ឋានរឹងមាំច្បាស់លាស់ ដើម្បីអនុវត្តកម្មវិធីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាទ្រង់ទ្រាយធំ។ ប៉ុន្តែ ដូចដែលយើងទាំងអស់គ្នាបានដឹងហើយថា កម្មវិធីនេះអាចដំណើរការទៅបាន លុះត្រាណាតែយើងអាចកៀរគរធនធានហិរញ្ញវត្ថុបានគ្រប់គ្រាន់ជាមុន។

នៅថ្នាក់ពិភពលោក ទឹកប្រាក់ចំណាយទៅលើសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុត្រូវបានគេប៉ាន់ស្មានថា មានប្រមាណពី៤០ ទៅ៥០០ពាន់លានដុល្លារសហរដ្ឋអាមេរិក ក្នុងមួយឆ្នាំៗ។ បើទោះបីជាបណ្តាប្រទេសអភិវឌ្ឍន៍ធ្វើតាមការសន្យា ដែលខ្លួនបានប្រកាសនៅក្នុងសន្និសិទលើកទី១៦ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុនៅឆ្នាំ២០១០ ក្តី ក៏កង្វះខាតថវិកានៅតែជាបញ្ហាចោទ ព្រោះថាទឹកប្រាក់សរុបដែលអាចកៀរគរបានសម្រាប់ទ្រទ្រង់ការចំណាយក្នុងមួយឆ្នាំៗហូតដល់ឆ្នាំ២០២០ គឺមានតិចជាង១០០ពាន់លានដុល្លារសហរដ្ឋអាមេរិក ហើយក្នុងនោះ ទឹកប្រាក់មួយភាគធំនឹងត្រូវយកទៅប្រើប្រាស់ក្នុងគម្រោងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ជា ជាងលើការងារបន្សាំ។ សម្រាប់ប្រទេសកំពុងអភិវឌ្ឍ ដូចជាប្រទេសកម្ពុជា ដែលថ្មីៗនេះត្រូវបានគេចាត់ចូលក្នុងចំណោមប្រទេសចំនួន១០ ដែលងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុបំផុតនោះ ការធានាឱ្យមានគ្រប់គ្រាន់នូវថវិកាសម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ គឺជាការចាំបាច់បំផុត។ នេះមានន័យថា គម្លាតរវាងតម្រូវការ និងការផ្គត់ផ្គង់ហិរញ្ញប្បទាននៅតែមានទំហំធំ ដែលតម្រូវឱ្យ កម្ពុជាមានជាចាំបាច់នូវសមត្ថភាពគ្រប់គ្រាន់ក្នុងការទាក់ទាញហិរញ្ញប្បទាន

សំដៅធានាឱ្យបាននូវទីតាំង ដ៏រឹងមាំក្នុងការប្រកួតប្រជែងយកធនធានដែលមានកំរិតនៅថ្នាក់អន្តរជាតិ ដើម្បីបំពេញតាមតម្រូវការរបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

កម្ពុជាត្រូវការយន្តការដែលគួរឱ្យជឿទុកចិត្ត និងមានភាពទាក់ទាញ សម្រាប់ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ដើម្បីធានាប្រសិទ្ធភាពនៃការកៀរគរធនធានដែលមាន។ យើងបានបង្ហាញឱ្យឃើញរួចមកហើយ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ពីសមត្ថភាពរបស់យើងក្នុងការកៀរគរ និងគ្រប់គ្រងហិរញ្ញប្បទានពីប្រភពផ្សេងៗ រួមមានថវិកាពីមូលនិធិបន្សាំ មូលនិធិសម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួច មូលនិធិវិនិយោគប្រែប្រួលអាកាសធាតុ ក៏ដូចជាមូលនិធិសម្រាប់ការងារប្រែប្រួលអាកាសធាតុពីសហភាពអឺរ៉ុប សហរដ្ឋអាមេរិក ជប៉ុន ស៊ុយអែត កូរ៉េខាងត្បូង និងបណ្តាប្រទេសផ្សេងៗទៀត។ ជារួមទឹកប្រាក់ប្រមាណ២៥០ លានដុល្លារសហរដ្ឋអាមេរិក ត្រូវបានកៀរគរយកមកប្រើប្រាស់ក្នុងរយៈពេលបីឆ្នាំកន្លងមក។ ក្នុងពេលជាមួយគ្នានោះ ការពិនិត្យទៅលើចំណាយសាធារណៈពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ដែលត្រូវបានធ្វើឡើងក្នុងឆ្នាំ២០១២ បានបង្ហាញឱ្យឃើញថា ប្រហែល១៦% នៃការចំណាយសរុបគឺបានមកពីថវិកាជាតិ ឧទាហរណ៍ដូចជាតាមរយៈការវិនិយោគទៅលើការឆ្លើយតបនឹងគ្រោះមហន្តរាយ ឬហេដ្ឋារចនាសម្ព័ន្ធជនបទ។

នៅពេលដែលលំហូរធនធានហិរញ្ញវត្ថុ សម្រាប់គ្រប់គ្រងបញ្ហាអាកាសធាតុ កាន់តែរីកធំឡើង យើងត្រូវបង្កើតយន្តការសម្រាប់ពង្រីកការងារឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ឱ្យស្របទៅនឹងថវិកាដែលទទួលបាន។ រហូតដល់ឆ្នាំ២០២០ គេរំពឹងថា ហិរញ្ញប្បទានអាកាសធាតុ នឹងកើនឡើងប្រហាក់ប្រហែលទៅនឹងថវិកាសរុប របស់ជំនួយអភិវឌ្ឍន៍ផ្លូវការ ដែលកំពុងត្រូវបានចំណាយនាពេលបច្ចុប្បន្ននៅទូទាំងពិភពលោក។ ដូច្នេះ ជាប្រការសំខាន់បំផុតក្នុងការធានាឱ្យបាននូវការគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាព ស្របតាមគោលការណ៍នៃសេចក្តីប្រកាសទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពជំនួយ ។ ខ្ញុំរំពឹងថា ក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ដែលបច្ចុប្បន្នកំពុងត្រូវបានអភិវឌ្ឍនឹងដើរតួជាមគ្គុទេសន៍ដឹកនាំឱ្យសម្រេចបាននូវគោលបំណងនេះ ប៉ុន្តែខ្ញុំក៏មានបំណងចង់ចែករំលែកជាគោលគំនិតមួយចំនួន ទាក់ទងនឹងតួនាទីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការរួមចំណែកគ្រប់គ្រងហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ នាពេលអនាគត។

ដើម្បីធានាបាននូវភាពជាម្ចាស់របស់ជាតិ ការបែងចែកធនធានយកទៅប្រើប្រាស់គួរតែធ្វើឡើងឱ្យស្របទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជាពិសេសស្របជាមួយនឹងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា។

បច្ចុប្បន្ន ហិរញ្ញប្បទានាភាគច្រើនត្រូវបានផ្តល់មកសម្រាប់តែដំណើរការគម្រោងមួយៗ ដាច់ដោយឡែកពីគ្នា។ នៅរយៈពេលពីរបីឆ្នាំទៅមុខទៀត យើងចង់ឱ្យមានការវិវត្ត ដោយធ្វើការផ្លាស់ប្តូរបន្តិចម្តងៗ ពីវិធីសាស្ត្រដែលមានមូលដ្ឋានផ្អែកលើគម្រោងមួយៗ ទៅជាវិធីសាស្ត្រដែលផ្តោតលើកម្មវិធី។ ចាំបាច់ត្រូវជម្រុញយន្តការមូលនិធិបែបប្រមូលផ្តុំ ក៏ដូចជាការគាំទ្រថវិកាតាមវិស័យ។ តាមរបៀបនេះ វានឹងជួយយើងក្នុងការគ្រប់គ្រងកំណើននៃលំហូរធនធាន ដោយបញ្ចៀសការចំណាយប្រតិបត្តិការហួសកំណត់ ដែលកើតឡើងដោយសារកំណើនយ៉ាងឆាប់រហ័សនៃចំនួនគម្រោង។

លើសពីនេះ វិធីនេះក៏នឹងជួយយើងក្នុងការដាក់បញ្ចូលការងារប្រែប្រួលអាកាសធាតុ ទៅក្នុងការធ្វើផែនការ និងការឡើងថវិកាដើម្បីអភិវឌ្ឍន៍។ យើងគួរកំណត់គោលដៅថា នៅក្នុងថេរវេលា១០ឆ្នាំទៅមុខ យើងនឹងលែងមានយន្តការហិរញ្ញប្បទាន ឬគម្រោងការប្រែប្រួលអាកាសធាតុដាច់ដោយឡែកៗពីគ្នាទាំងស្រុង។ មានន័យថា ការប្រែប្រួលអាកាសធាតុគួរតែត្រូវបានប្រើជាលក្ខណៈវិនិច្ឆ័យស្តង់ដារ នៅក្នុងរាល់សកម្មភាពធ្វើផែនការវិនិយោគ ទាំងសាធារណៈនិងឯកជន និងទៅក្នុងការរៀបចំថវិការបស់យើង។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងសហការជាមួយគ្រប់ក្រសួងពាក់ព័ន្ធ និងជាមួយក្រសួងបរិស្ថាន ដើម្បីធានាឱ្យបានថា យើងមានការយល់ដឹងគ្រប់ជ្រុងជ្រោយអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើការវិនិយោគតាមផែនការ និងអំពីវិធានការបច្ចេកទេស ដើម្បីដោះស្រាយផលប៉ះពាល់ទាំងនេះ។ ប្រការនេះនឹងជួយតម្រង់ទិសដៅការប្រើប្រាស់ធនធានដែលមានក្នុងស្រុក និងដែលទទួលបានពីម្ចាស់ជំនួយ សម្រាប់អនុវត្តតែការងារវិនិយោគណា ដែលផ្តល់នូវអត្ថប្រយោជន៍ច្រើនបំផុតដល់សេដ្ឋកិច្ច និងសង្គមកម្ពុជា នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។ ជាមួយគ្នានេះ យើងក៏ត្រូវធ្វើការពង្រឹងសមត្ថភាពក្នុងការតាមដានហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ និងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានទាំងនោះ ដើម្បីឱ្យដៃគូអភិវឌ្ឍន៍មានទំនុកចិត្ត និងបន្តផ្តល់ជំនួយ តាមរយៈប្រព័ន្ធជាតិរបស់យើង។

គោលដៅចំបងសម្រាប់ប្រទេសកម្ពុជានាពេលរយៈពេលពីរទៅបីឆ្នាំបន្ទាប់នេះ គឺទទួលបាននូវហិរញ្ញប្បទានផ្ទាល់ពីមូលនិធិអាកាសធាតុសកល ដូចជា មូលនិធិបន្សាំ និងមូលនិធិអាកាសធាតុបៃតង តាមរយៈការជម្រុញឱ្យមានការទទួលស្គាល់ជាផ្លូវការនូវអង្គភាពអនុវត្តន៍ជាតិ។

សម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បញ្ហាគន្លឹះមួយផ្សេងទៀត គឺការរក្សាឱ្យបាននូវការពិភាក្សាប្រកបដោយលទ្ធផលផ្លែផ្កា ជាមួយវិស័យឯកជន លើការលើកកម្ពស់បរិយាកាសវិនិយោគមួយដែលមានអំណោយផលដល់អាជីវកម្មបៃតង។ វិស័យឯកជនដើរតួនាទីយ៉ាងសំខាន់នៅស្ទើរតែគ្រប់ផ្នែកទាំងអស់នៃផែនការយុទ្ធសាស្រ្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា។ ឧទាហរណ៍ខ្លះៗ ដូចជា ការអភិវឌ្ឍថាមពលកកើតឡើងវិញ ប្រសិទ្ធភាពថាមពលនៅក្នុងឧស្សាហកម្មនិងកសិឧស្សាហកម្ម ប្រសិទ្ធភាពថាមពលក្នុងវិស័យសាងសង់ ហេដ្ឋារចនាសម្ព័ន្ធធន់នឹងអាកាសធាតុ និងផ្នែកផ្សេងៗទៀតជាច្រើន។ យើងមានកាតព្វកិច្ចក្នុងការធានាថា ប្រទេសកម្ពុជាផ្តល់នូវបរិស្ថានអំណោយផលមានស្ថេរភាព និងសន្តិសុខ សម្រាប់ការវិនិយោគបៃតង ដើម្បីឱ្យយើងអាចបង្កើនហិរញ្ញវត្ថុពីប្រភពឯកជនដើម្បីជួយដល់ការសម្រេចគោលដៅចំបងរបស់យើង
ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ជាទីគោរព*

ដូចដែលយើងទាំងអស់គ្នាបានឃើញក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ហើយក៏ដូចជាគ្រោះទឹកជំនន់ដែលទើបនឹងកើតឡើងនៅប៉ុន្មានសប្តាហ៍ថ្មីៗនេះ ប្រទេសកម្ពុជាបានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងររួចទៅហើយពីការប្រែប្រួលអាកាសធាតុ ដែលកើតមានកាន់តែញឹកញាប់ និងធ្ងន់ធ្ងរជាងមុន។ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើវិភាជន៍ថវិកាយ៉ាងច្រើន សម្រាប់ទ្រទ្រង់ដល់កិច្ចខិតខំប្រឹងប្រែងគ្រប់

គ្រងគ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុ ហើយក៏បានធ្វើការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការគាំទ្រដល់ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅពេលអនាគត។

ទោះជាយ៉ាងនេះក្តី ក្នុងនាមជាប្រទេសអភិវឌ្ឍតិចតួច និងជាប្រទេសមួយដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុ កម្ពុជាប្រឈមមុខនឹងបញ្ហាចោទជាច្រើន រួមទាំងកង្វះសមត្ថភាពផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ។ ដូច្នេះ ការអនុវត្តនូវផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ជាអ្វីដែលយើងបានពិភាក្សាអស់រយៈពេលពីរថ្ងៃកន្លងមកនេះ នឹងតម្រូវឱ្យមាននូវភាពជាដៃគូដ៏រឹងមាំជាមួយភាគីពាក់ព័ន្ធខាងក្រៅ។

ខ្ញុំសង្ឃឹមថា ថ្ងៃចុងក្រោយនៃវេទិកានេះនឹងផ្តល់នូវឱកាសឱ្យយើងធ្វើការពិភាក្សាអំពីថា តើយើងត្រូវការភាពជាដៃគូបែបណា តើយើងត្រូវរៀបចំផែនការកៀរគរធនធានចាំបាច់បែបណា និងតើគួរគ្រប់គ្រងធនធានទាំងនោះឱ្យមានប្រសិទ្ធភាព និងប្រកបដោយការសម្របសម្រួលបែបណា។ ខ្ញុំមានជំនឿជឿជាក់ថា ដៃគូអភិវឌ្ឍន៍យើង និងភាគីពាក់ព័ន្ធទាំងអស់នឹងគាំទ្រ ហើយចូលរួមសហការពេញទំហឹង ក្នុងកិច្ចស្វែងរកដំណោះស្រាយបញ្ហាប្រឈមដ៏ចំបងនៃយុគសម័យកាលយើងនេះ។

សូមអរគុណ។